**Program:** Crime Before Bed

**Topic:** Elizabeth Short ( ការស្លាប់យ៉ាងអាថ៌កំបាំងរបស់ Elizabeth Short )

**Categories:** Crime Investigation

**Publish Date:** Wednesday 20th, August 2021

**Content by:** Prey Reung



--------------------------------------------------------------------------------

**Hook:**

សូមស្វាគមន៍មកកាន់ CamID Podcast!

ការស្លាប់យ៉ាងអាថ៌កំបាំងរបស់ Elizabeth Short អស់រយះពេល ៧០ ឆ្នាំ ដែលមិនអាចស្រាយចំងល់បាន។

**Intro:**

ក្រោយពីហេតុការណ៍ សង្គ្រាមលោកលើកទីពីរបានបញ្ចប់ រយះពេលពីរឆ្នាំក្រោយមក ពោលគឺ នៅឆ្នាំ១៩៤៧ នារីដ៏ស្រស់ស្អាតម្នាក់ត្រូវបានឃាតកដៅផៅ សម្លាប់យ៉ាងសាហាវព្រៃផ្សៃជាទីបំផុតនៅលើដឹកដីរដ្ឋ California នៃ សហរដ្ឋអាមេរិក។

ហេតុការណ៏ដ៏រន្ធត់ព្រឺព្រួចនេះ បានដក់ជាប់នៅក្នុងចិត្តប្រជាជនអាមេរិក រួមទាំងក្រុមការងាររបស់ព្រៃរឿងផងដែរ ព្រោះថារឿងរ៉ាវដែលឃាតករបានធ្វើទៅលើសាកសព Elizabeth មិនអាចធ្វើអោយប្រជាជនអាមេរិក និងព្រៃរឿងទទួលយកបាននោះទេ

មិនត្រឹមតែប៉ុណ្ណោះ ហេតុការណ៏នេះ ក៏បានធ្វើអោយក្រុមប៉ូលិសស៊ើបអង្កេត FBI ចំណាយពេលស៊ើបអង្កេតអស់រយះពេលជាង៧០ឆ្នាំហើយ នៅតែមិនអាចដោះស្រាយចេញរហូតមកដល់បច្ចុប្បន្ន។

**Body**:

រឿងរ៉ាវនេះត្រូវបានគេចងក្រងជាសៀវភៅហើយ ក៏លក់ដាច់បំផុតក្នុងដើមសតវត្សទី ២០ ផងដែរ។ ព្រោះរឿងសង្ឃឹមថា អ្នកទាំងអស់គ្នាស្តាប់យ៉ាងយកចិត្តទុកដាក់ និងធ្វើចិត្តដើម្បីទទួលយកហេតុការណ៍មួយនេះ។

តែមុន នឹងចូលទៅដល់សាច់រឿងស៊ីជម្រៅ ព្រោះរឿងចង់សង្ខេបពីខ្សែជីវិតដ៏កម្សត់ និងការតស៊ូរបស់ Elizabeth ជាមុនសិន។

រឿងរ៉ាវនេះ ផ្តើមចេញពីនារីម្នាក់ ដែលមានឈ្មោះថា Elizabeth Short និងរហ័សនាមហៅក្រៅថា Black Dahlia ភាគច្រើនគេហៅឈ្មោះនេះ តាមរយៈរឿង "The Blue Dahlia" ដោយនាងចូលចិត្តពណ៌ខ្មៅផងនោះ ទើបនាងជាប់ឈ្មោះថា Black Dahlia រហូតមកដល់សព្វថ្ងៃ។

Elizabeth កើតនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩២៤ នាងកើតនៅក្នុងគ្រួសារក្រីក្រមួយ នៅក្នុងទីក្រុង Boston រដ្ឋ Massachusetts នៃសហរដ្ឋអាមេរិក។ នាងមានបងប្អូន ៥នាក់ សុទ្ធតែជាស្រី ដែលនៅក្នុងគ្រួសារនោះនាងជាកូនទី៣។ ម្តាយរបស់នាងឈ្មោះ Phoebe Short ចំណែកឯឪពុករបស់នាងឈ្មោះថា Cleo។

លុះនៅពេលនាងមានអាយុ៦ឆ្នាំ គ្រួសាររបស់នាងបានជួបវិបត្តហេរញ្ញវត្ថុជាខ្លាំង ដោយមានវិបត្តផ្លូវចិត្ត និងមិនអាចស៊ូទ្រាំជាមួយនឹងការងារជាអ្នកសាងសង់ និងរៀបចំកន្លែងវាយកូនហ្គូលតទៅទៀត ឪពុករបស់នាង គឺ Cleo ក៏បានសម្រេចចិត្តបោះបង់ និងរត់ចោលគ្រួសារមួយនេះ។

បន្ទាប់មក គ្រួសារនេះកាន់តែជួបការលំបាកច្រើនទៅៗ។ នៅពេលដែលនាងធំដឹងក្តី នាងក៏បានចាប់ផ្តើមជីវិតនៅសកលវិទ្យាល័យ ក៏ប៉ុន្តែនាងបានសម្រេចចិត្តបោះបង់ការសិក្សាចោលនៅឆ្នាំទីមួយតែម្តង រួចក៏សម្រេចចិត្ត ដើរតាមក្តីស្រម៉ៃរបស់នាងដោយ នាងទៅធ្វើការជាអ្នកបម្រើ និងអ្នកទទួលភ្ញៀវ ក្នុងរោងភាពយន្តមួយដែលស្ថិតនៅក្នុង Los Angeles រដ្ឋ Californiaវិញ ព្រោះនាងមានក្តីស្រម៉ៃចង់ក្លាយជាជាអ្នកសម្តែងរឿងជាយូរមក ហើយ

នេះគឺជាពេលមួយដែលនាងត្រូវឃ្លាតឆ្ងាយពីបងប្អូននិងក្រុមគ្រួសារ។ រីឯក្តីស្រម៉ៃមួយនេះត្រូវបានរលាយសាបសូន្យនៅពេលដែលនាងលាចាកលោកទៅក្រោមថ្វីដៃរបស់ឃាតក ព្រៃផ្សៃ។

បើនិយាយពីសម្រស់របស់ Elizabeth វិញ នាងជានារីម្នាក់ដែលមានរូបសម្រស់ស្រស់ស្អាត ប៉ុន្តែនាងមានជម្ងឺប្រចាំកាយម៉្យាង គឺជម្ងឺហឺត។

នាងតែងតែមានបុរសជាច្រើនតាមសុំស្នេហ៍ផងដែរ។ នៅពាក់កណ្តាលឆ្នាំ១៩៤០ កំឡុងពេលអាមេរិកកំពុងតែមានសង្គ្រាមលោក នាងក៏បានធ្វើដំណើរទៅកាន់រដ្ឋ Florida ដើម្បីគេចខ្លួនពីខែធ្លាក់ខ្យល់ ឬជាភាសាអង់គ្លេសថា New England Winters ព្រោះនាងមានជម្ងឺហឺត។ នៅឆ្នាំ១៩៤៣ ពោលគឺនាងមានអាយុ ១៩ឆ្នាំ នាងត្រូវបានប៉ូលិសក្រុង Santa Barbara ចាប់ខ្លួនពីបទមិនទាន់គ្រប់អាយុផឹកស្រា ក្រោយមកនាងក៏ត្រូវបានដោះលែង បន្ទាប់ពីឃុំខ្លួនអស់មួយរយៈ រួចនាងក៏ត្រូវប៉ូលិសបញ្ជូនមក ស្រុកកំណើតវិញ។

គួបញ្ជាក់ផងដែរថា នៅពេលដែរនាងស្នាក់នៅ Florida ពេលនោះនាងក៏បានជួបបុរសម្នាក់ ដែលមានឈ្មោះថា Matt Gordon Jr។ Gordon គឺជាទាហានកងទ័ពអាកាស ហើយលោក ក៏ជាអ្នកបើកបរយន្តហោះផងដែរ។

ក្រោយមកឆ្នាំ១៩៤៥ Gordan ត្រូវបំពេញភារកិច្ចរបស់ខ្លួន ដោយលោកត្រូវហោះទៅកាន់ប្រទេសឥណ្ឌា កំឡុងពេលលោកនៅប្រទេសឥណ្ឌា លោកក៏បានសរសេរសំបុទ្រសុំរៀបការជាមួយ Elizabeth។

Elizabeth មិនបានរារែកក្នុងការសម្រេចចិត្តថាព្រមនោះទេ នាងថែមទាំងសរសេរសំបុត្រចំនួន២៧ច្បាប់ទៅវិញផងដែរ តែជាអកុសល Gordon ត្រូវបានស្លាប់ដោយសារការធ្លាក់យន្តហោះ នៅពេលលោកហោះទៅកាន់ទឹកដីសហរដ្ឋអាមេរិកវិញ។

ដំណឹងដ៏ក្រៀមក្រំមួយនេះ ត្រូវបានលេចឮទៅដល់ Elizabeth អំឡុងពេលដែលនាងធ្វើជាអ្នកបម្រើនៅទឹកដីកំណើតរបស់នាង ហើយនាងមិនអាចទទួលយកវាបានទេ ព្រោះវាលឿនពេកសម្រាប់នាង។

សំណួរសួរថា តើខ្សែជីវិតរបស់ Elizabeth ទៅជាយ៉ាងណា បន្ទាប់ពី Gordon ស្លាប់?

ចាប់តាំងពីពេលនោះមក Elizabeth ក៏បានកើតទុក្ខក្រៀមក្រំយ៉ាងខ្លាំង នាងមិនអាចដកខ្លួនចេញពីការឈឺចាប់មួយនេះបានទេ។

អស់រយះពេល ១ឆ្នាំកន្លះ ដោយនាងមិនអាចប្រឈម នឹងការឈឺចាប់ និងជម្ងឺបាក់ទឹកចិត្តមួយនេះបាន នាងក៏បានបណ្តោយអោយជីវិតនាង រសាត់អណ្តែតពាសពេញទីកន្លែងដោយគ្មានគោលដៅ ហើយនាងក៏មិនបានធ្វើការងារអ្វីដែរ គឺនាងស្នាក់អាស្រ័យជាមួយមិត្តភក្តិ និងអ្នកជិតដិតរបស់នាងតែប៉ុណ្ណោះ។

ក្រោយមក នារដូវក្តៅឆ្នាំ១៩៤៦ នាងបានទៅដល់ Long Beach ក្នុងគោលបំណងសាងស្នេហ៍ជាថ្មីម្តងទៀតជាមួយបុរសម្នាក់ ដែលជា Pilot ដូចអតីតសង្សារនាងគឺលោក Gordon ដែរ។ ប៉ុន្តែ ស្នេហាមួយនេះមិនសមបំណងនាងទេ។ ចាប់តាំងពីពេលហ្នឹងមក នាងបានធ្លាក់ខ្លួនស្នាក់នៅ Apartment ជាមួយមិត្តភក្តរបស់នាង។

លុះនៅ ខែធ្នូ ឆ្នាំ១៩៤៦ នាងបានជួបនារីម្នាក់ដែលធ្វើការជាអ្នកគិតលុយនៅឯ San Diego នៅពេលដែលនារីម្នាក់នោះដឹងថា Elizabeth គ្មានកន្លែងស្នាក់នៅ។ នាងក៏បានចែករំលែកកន្លែងស្នាក់នៅអោយនាងជាមួយម្តាយ និងប្អូនប្រុសរបស់នាង។

Elizabethបានចំណាយពេលស្នាក់នៅមួយខែ ដោយនាងបានណាត់ជួបបុរសជាច្រើន។ បន្ទាប់ពីហ្នឹងមក នាងបានជួប បុរសជាឈ្មួញម្នាក់ឈ្មោះថា Robert Red Manley ហើយពួកគេទាំងពីរក៏បានចំណាយពេលមួយអាទិត្យជាមួយគ្នាក្នុងការណាត់ជួប។

ថ្ងៃមួយនាងក៏បានទៅដើរលេងជាមួយ Manley នៅឯ Los Angeles ហើយបានស្នាក់នៅផ្ទះសំណាក់មួយយប់នៅទីនោះយ៉ាងសប្បាយរីករាយ។

នៅថ្ងៃទី៩ ខែមករា ឆ្នាំ១៩៤៧ ដោយនាងចង់ចាកចេញពី Manley នាងក៏បានប្រឌិតរឿងឡើងថានាងត្រូវទៅជួបបងស្រីរបស់នាងនៅឯសណ្ឋាគារ Biltmore។

ដូច្នេះ Manley ក៏បានដឹក Elizabeth ទៅទម្លាក់នៅសណ្ឋាគារនាយប់នោះតែម្តង។ ខ្សែជីវិតរបស់នាងក៏បានកាត់ផ្តាច់នាយប់នៅសណ្ឋាគារ Biltmore ហើយក៏ជាយប់ និងជាកន្លែងចុងក្រោយដែលនាងបានបាត់ខ្លួនពីក្រសែភ្នែកមនុស្សជុំវិញខ្លួននាង។

តើមានរឿងអ្វីកើតឡើងចំពោះនាងបន្ទាប់នាងបានបាត់ខ្លួន? មកដល់ចំណុចនេះ ប្រិយអ្នកស្តាប់របស់ព្រៃរឿងត្រូវស្តាប់យ៉ាងយកចិត្តទុកដាក់ និងធ្វើចិត្តដើម្បីទទួលយកហេតុការណ៍ដ៏រន្ធត់មួយនេះ។

នាថ្ងៃទី១៥ ខែមករា ១៩៤៧ ពោលគឺបន្ទាប់ពីនាងបានបាត់ខ្លួនអស់ ៦ថ្ងៃ។ វេលាម៉ោងប្រហែល១០ព្រឹក នារីម្នាក់ឈ្មោះ Betty Bersinger ដែលកំពុងរុញរទេះជូនកូនស្រីអាយុ ៥ឆ្នាំ របស់នាងដើរលេងតាមបណ្តោយផ្លូវឧទ្យានសារធារណៈមួយ គឺ Leimert Park ភាគខាងត្បូងនៃ Los Angeles រដ្ឋ California។

ស្រាប់តែភ្លាមនោះនាងបានប្រទះឃើញអ្វីម្យ៉ាង ដែលមានសភាពពណ៌សរ នៅលើស្មៅតាមបណ្តោយផ្លូវនោះ នាងបានលាន់មាត់ថា "ចុម អីគេនោះ?"

រូបភាពបានផុសឡើងកាន់តែច្បាស់ នៅពេលដែលនាងដើរទៅជិត។

នាងបានឃើញសាកសពនារីម្នាក់ដែលដេក ដោយគ្មានសម្លៀកបំពាក់ នៅលើស្មៅនោះ អ្វីដែលកាន់តែធ្វើអោយនាងកាន់តែខ្លាច គឺសាកសពនោះត្រូវបានឃាតក កាត់ផ្តាច់ខ្លួនចេញជាពីរកំណាត់ត្រឹមចង្កេះ និងត្រូវបានរៀបដាក់តាមលំដាប់លំដោយថែមទៀតផង

វាមើលទៅដូចជានារីម្នាក់កំពុងដេកនៅលើផ្លូវ ដោយដៃទាំងពីរដាក់ឡើងលើ។

ដំបូង Betty ស្មានតែម៉ាឡាកាំង តែដល់ពេលដឹងច្បាស់ នាងមិនចាំយូរឡើយ។ នាងក៏បានចាប់ដៃកូនស្រីរបស់នាង រត់ទៅតេទូរស័ព្ទរ៉ាយរ៉ាប់ប្រាប់អំពីរឿងហ្នឹង ទៅកាន់ប៉ុស្តប៉ូលិស Los Angeles ដែលហៅកាត់ថា LADP។

មិនយូរប៉ុន្មានប៉ូលិស និងអ្នកធ្វើកោសល្យវិច្ច័យក៏បានមកដល់ ក្រុមប៉ូលិសក៏បានចុះពិនិត្យសាកសព ហើយក៏បានធ្វើការអង្កេតទៅលើកុស្តតាងក្បែរនោះ ប៉ុន្តែមិនឃើញអ្វីក្រៅពីបាវច្រកព័ណ៌សរដែលឃាតករច្រកយកមកដាក់ចោលនៅទីនោះ ហើយនិងនាឡិកាដៃដែលនៅក្បែរនោះទេ។

ក្រៅពីនេះ ប៉ូលិសក៏បានប្រមូលបំណែកសាកសពទាំងប៉ុន្មានយកទៅពិនិត្យ។ ម្នាក់ក្នុងចំណោមប៉ូលិសនោះ គឺលោក Brian Carr បាននិយាយថា លោកមិនអាចស្រម៉ៃថា មនុស្សទៅសម្លាប់មនុស្សដូចគ្នាយ៉ាងសាហាវព្រៃផ្សៃបែបនេះទេ។

ស្នាមក្រយៅដៃរបស់សាកសពនោះក៏បានគូសបញ្ជាក់ថា នេះគឺជាសាកសពរបស់ Elizabeth Short ដែលពេលស្លាប់នាងមានអាយុទើបតែ២២ឆ្នាំតែប៉ុណ្ណោះ។

បើនិយាយអោយស៊ីជម្រៅទៅលើស្នាមរបួសលើសាកសព គឺថាសាកសពនាងត្រូវបានឃាតក កាត់ផ្តាច់ជាពីរត្រឹមចង្កេះ ហើយស្នាមកាត់នេះមានលក្ខណះស្អាតមិនរញ៉េរញ៉ៃ ដោយប៉ូលិសធ្វើការសន្នត់ដែរថា ឃាតក នេះប្រហែលជាមានជំនាញខាងវះកាត់ហើយ

ព្រោះការវះកាត់នេះ បានផ្ដាច់ខ្លួននាងចេញជាពីរ ដោយមិនមានការបាក់ឆ្អឹងខ្នងនោះទេ។
រីឯដំណក់ឈាមសម្បីតែមួយដំណក់ក៏មិនឃើញនៅកន្លែងសាកសពនោះដែរ
ដែលមានន័យថានាងត្រូវគេសម្លាប់នៅកន្លែងផ្សេងរួចយកមកដាក់ចោលកន្លែងនេះ។

ព្រៃរឿងសូមបញ្ជាក់ផងដែរថា នាងក៏ត្រូវបានឃាតករលោភ
និងធ្វើទារុណកម្មផ្លូវកាយយ៉ាងសាហាវឃោរឃៅថែមទៀតផង
មុនពេលដែលនាងត្រូវឃាទករចិត្តតិរច្ឆាននោះសម្លាប់។

រីឯមូលហេតុចំបងដែលធ្វើអោយនាងស្លាប់គឺក្បាលរបស់នាងហូរឈាមច្រើន
ហើយនាងត្រូវបានធក់រហូតដល់អស់ឈាមផងដែរ។ ចំណែកឯមុខរបួសកន្លែងផ្សេងមានដូចជា ក្បាល
កំភ្លៅ ដៃ មាត់ ហើយនិងជើងរបស់នាង ជាក់ស្ដែងគឺស្នាមនៅលើកដៃ កំភ្លៅ
និងឃ្នងជើងបញ្ជាក់ថានាងត្រូវបានឃាតករធ្វើទារុណកម្មមុនស្លាប់ថែមទៀតផង។

ជាងនេះទៅទៀតមាត់របស់នាងត្រូវបានគេវះទាំងសងខាងពីថ្ពាល់ដល់គុម្ពត្រចៀក
មើលទៅហាក់ដូចជាស្នាមញញឹមដ៏គួរអោយព្រឺព្រួចមួយ។

មុននឹងស្លាប់នាងត្រូវបានបង្ខំអោយស៊ីលាមក និងសាច់របស់ខ្លួននាង
ដែលសាច់នោះត្រូវបានគេដាពីកំភ្លៅរបស់នាងនោះឯង។ វាស្ដាប់ទៅ

មិនអាចធ្វើអោយយើងស្រម៉ៃពីការឈឺចាប់មួយនេះបានទេ។ នៅមានចំណុចផ្សេងទៀតដែលឃោឃៅ ប៉ុន្តែព្រៃរឿងសូមមិនលើកយកមកទេ។

ក្រោយពី ប៉ូលិសកំណត់អត្តសញ្ញាណជនរងគ្រោះបាន ការស៊ើបអង្កេតក៏ចាប់ផ្ដើមប្រតិបិត្តដោយមានក្រុមស៊ើបអង្កេតអន្តរជាតិ FBI ជាជំនួយផងដែរ។

បន្ទាប់ពី Elizabeth បានស្លាប់ ៩ថ្ងៃក្រោយមក មានស្រោមសំបុត្រមួយបានផ្ញើមកកាន់ប៉ុស្តប៉ូលិសដោយភ្ជាប់ជារបស់របរ Elizabeth មានដូចជាសំបុត្រកំណើត រូបថត និងសៀវភៅអាស័យដ្ឋាន ដែលនៅក្នុងសៀវនោះ ក៏មានទំព័រមួយចំនួនបានកាត់បាត់ផងដែរ។

វត្ថុទាំងអស់នៅក្នុងនោះ មិនមានស្នាមក្រយៅដៅនោះទេ ព្រោះត្រូវបានគេសំអាត និងលុបក្រយៅដៅជាមួយនិងប្រេងសាំងបាត់ទៅហើយ។ ចំណែកស្រោមសំបុត្រវិញ គេប្រើប្រាស់អក្សរដែលកាត់ចេញពីកាសែតយកមកផ្គុំគ្នាដោយសរសេរថា "នេះគឺជារបស់របរ Dahlia"។

សរុបទាំងអស់គឺមានសំបុត្រចំនួន ១៣ច្បាប់ក្នុងស្រោមសំបុត្រនោះ ដែលបានផ្ញើទៅកាន់ប៉ូលិស។

១ច្បាប់ក្នុងចំណោមនោះបានសរសេរដោយការកាត់សន្លឹកពីក្រដាស់កាសែតផ្គុំគ្នាមានអត្ថន័យថា "I will give Dahlia if i get ten years.don’t try to find me!"

ចំណែកឯ ១ច្បាប់ទៀតបានសរសេរជាលាយលក្ខអក្សរដោយផ្ទាល់ដៃថា ”Here it is! Had my fun at police; Black Dahlia Avenger.” ប៉ូលិសបានសង្ស័យថាអ្នកដែលផ្ញើនោះប្រាកដជាឃាតករហើយ។

រឿងរ៉ាវនេះបានក្លាយទៅជាដំណើរផ្សេងរបស់ប៉ូលិស។

ប៉ូលិសបានធ្វើការសាកសួរក្រុមសិស្សនិសិត្សផ្នែកពេទ្យ នៅឯសកលវិទ្យាល័យពេទ្យ Southern California Medical School ជាង៣០០នាក់ ក៏ប៉ុន្តែមិនបានផលនោះទេ។

រីឯអស័យដ្ឋាន និងឈ្មោះបុរសដែលមាននៅសៀវភៅអស័យដ្ឋានរបស់នាងប្រហែល ៧៥នាក់ គឺត្រូវបានប៉ូលិសសាកសួរហើយក៏ប៉ុន្តែក៏មិនមាននណារម្នាក់ពាក់ព័ន្ធនិងករណីឃាតកម្មនេះដែរ។

ភាគច្រើនពួកគេឆ្លើយថា វាគ្រាន់តែជាការណាត់ជួប ហើយញ៉ាំអីជាមួយនាងតែប៉ុណ្ណោះ ក្រោយពីហ្នឹងមក ពួកគេមិនដែលបានជួបនាងទៀតទេ។

ក្រោយពីការស៊ើបអង្កេតបានអូសបន្លាយអស់រយះជាង៧០ឆ្នាំមក បើយើងគិតមកដល់បច្ចុប្បន្ន គឺមានជនសង្ស័យសំខាន់ៗចំនួន៣នាក់គឺ អ្នកទីមួយលោក Manley ដែលត្រូវជាសង្សារចុងក្រោយរបស់ Elizabeth។

Manleyត្រូវបានប៉ូលិសសួរពីរលើកដោយលើកទី១លោកត្រូវបានប៉ូលិសជឿជាក់ថាលោកមិនបានពាក់ព័ន្ធរឿងក្តីនេះទេ។ ចំណែកឯលើកទី២ គឺនៅ ឆ្នាំ១៩៥៤ Manley ត្រូវបានពេទ្យវិកលចរិកដាក់ថ្នាំសារភាពការពិត ក៏ប៉ុន្តែការឆ្លើយរបស់លោកនៅតែបង្ហាញថាលោកមិនជាប់ពាក់ព័ន្ធដ៏ដែរ។ នៅថ្ងៃទី៩ ខែមករា ឆ្នាំ១៩៨៦លោកបានស្លាប់ដោយធ្លាក់ពីលើផ្ទះរបស់លោកចែដន្យ។

ចំពោះជនសង្ស័យ ទី២ វិញ គឺមាននៅក្នុងកច្ចសម្ភាស៍របស់លោក Ralph Asdel។ សូមបញ្ជាក់ផងដែរថាលោក Asdel គឺជាអ្នកស៊ើបអង្កេតម្នាក់ដែលចំណាយពេល៥០ឆ្នាំជាងទៅលើករណីមួយនេះ ចាប់តាំងពី១៩៤៧មក ហើយលោកក៏ជាអ្នកស៊ើបអង្កេតចុងក្រោយ ដែលមាននៅរស់ក្នុងចំណោមអ្នកស៊ើបអង្កេតផ្សេងទៀត ។

ក្រោយពីថ្ងៃកើតហេតុបានមួយអាទិត្យ លោកបាននិយាយប្រាប់ទៅកាន់LA Time ថាលោកបានរកឃើញជនសង្ស័យម្នាក់ដែលលោកដែលមានកិនភាគដូចទៅនឹងការរៀបរាប់របស់សាក្សីក្បែរនោះ ប៉ុន្តែលោកមិនមានកុស្តតាំងដាក់លាក់ដើម្បីចោទប្រកាន់ម្នាក់នោះបានទេ។

គួរបញ្ជាក់ផងដែរថាសាក្សីនិយាយប្រាប់ Asde lថានាពេលទាបភ្លឺគាត់បានឃើញបុរសម្នាក់ជិះឡានព័ណ៌ខ្មៅហើយចតឡានក្បែរកន្លែងដែលគេរកឃើញសាកសព Elizabeth នោះ។ រហូតដល់ ឆ្នាំ១៩៩៧ Asdel នៅតែជឿជាក់ថាបុរសម្នាក់នោះគឺជាអ្នកសម្លាប់Elizabeth។

ក្រៅពីនេះ គឺនៅមានជនសង្ស័យសំខាន់ចុងក្រោយ ដែលជាបុគ្គលម្នាក់ដែល ត្រូវមហាជនអាមេរិកជាច្រើនបានស្គាល់ និងបានស្ញើចសរសើរចំពោះស្នាដៃឯកទេសផ្នែកវះកាត់របស់លោកផងដែរ។ លោកមានឈ្មោះថា Dr. George Hodel។

លោក Hodel ត្រូវបានគេស្គាល់ថាជាមនុស្សអស្ចារ្យ និងមានភាពឆ្លាតវៃ (IQ)ខ្ពស់ថែមទៀតផង មិនតែប៉ុណ្ណោះលោកក៏ជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម និងផ្ទះធំស្កឹមស្កៃផង។ Hodel គឺជាវេជ្ជបណ្ឌិតផ្នែកវះកាត់ម្នាក់ ដែលល្បីល្បាញនាសម័យនោះ។

ដោយសាកសពរបស់ Elizabeth ត្រូវបានកាត់ផ្ដាច់ជាពីរត្រឹមចង្កេះយ៉ាងស្អាត ភាគច្រើនជនសង្ស័យសុទ្ធតែជាគ្រូពេទ្យ។

សំណួរសួរថា ហេតុអ្វីបានជាគេសង្ស័យទៅលើយ លោក Hodel ទៅវិញ? ចំលើយនោះគឺថា នៅឆ្នាំ១៩៤៩ រំលងពីរឆ្នាំបន្ទាប់ពី Elizabethban ស្លាប់ លោក Hodel មានបញ្ហាស្នេហារការំរកោសជាមួយកូនស្រីខ្លួនឯងគឺ Tamar Hodel។

គ្រានោះដំណឹងនេះក៏លេចលឺដល់ក្រុមប៉ុលិស LA ហើយកេរ្តិ៍ឈ្មោះរបស់លោកក៏ត្រូវបានធ្លាក់ចុះ រីឯឈ្មោះរបស់គាត់ជាប់ជាឈ្មោះលំដាប់កំពូលក្នុងបញ្ជីឈ្មោះជនសង្ស័យក្នុងក្តីឃាទកម្មរបស់

Elizabeth។ ទោះជាយ៉ាងណាក៏ដោយក៏ឈ្មោះលោកមិនត្រូវបានប្រកាសជាសារធារណៈដែរ ព្រោះជំនាន់នោះពោរពេញទៅដោយអំពើពុករលួយនៅសហរដ្ឋអាមេរិក។

រឿងរ៉ាវមិនទាន់ចប់ត្រឹមនេះទេ ក្រោយពីលោក Hodel បានស្លាប់ដោយសារជម្ងឺគាំងបេះដូងនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៩៩។ ការស៊ើបអង្កេតទៅលើលោក Hodel ក៏ផ្ទុះឡើងម្តងទៀត។

ប៉ុន្តែការស៊ើបអង្កេតម្តងនេះ ស៊ីជម្រៅជាងមុន ព្រោះការស៊ើបអង្កេតលើកនេះគឺធ្វើឡើងដោយកូនប្រុសគាត់ផ្ទាល់ ដែលមានឈ្មោះថា Steve Hodel។

មកដល់ចំណុចនេះ ព្រៃរឿងសូមបញ្ជាក់ផងដែរថា Steve ជាអតីតអ្នកស៊ើបអង្កេតក្តីឃាតកម្មនៅLADP ហើយលោកបានចូលនិវត្តន៍តាំងពីឆ្នាំ១៩៨៦មកម្ល៉េះ។

លោកបានសិក្សាលើរឿងក្តីឃាតកម្មជាង៣០០ករណីមកហើយ។ នៅពេលដែល Elizabeth ស្លាប់លោកទើបតែមានអាយុ៦ឆ្នាំតែប៉ុណ្ណោះ។ លោកបានចំណាយពេលអស់១៥ឆ្នាំដើម្បីរកភស្តុតាងចោទឪពុករបស់លោក ហើយលោកក៏មិនមែនធ្វើតែអោយរួចពីដៃនោះដែរ។

តើSteveបានរកឃើញអ្វីខ្លះចំពោះឪពុករបស់គាត់?

នៅពេល Steve ទៅប្រមូលទព្យសម្បត្តិពីផ្ទះឪពុកគេបន្ទាប់ពី Hodel បានស្លាប់ Steve បានរកឃើញអាលប៊ុមរូបថតស្រីៗជាច្រើន ហើយមានរូបថតមួយសន្លឹកមើលទៅស្រដៀងគ្នាទៅនឹង Elizabethអីចឹង។

លោកកាន់តែសង្ស័យ ហើយក្រោយមកទៀតលោករកឃើញថា Hodel ធ្លាប់មានទំនងទំនងជាមួយឪពុករបស់នាងកាលពីឆ្នាំ១៩៤៤ផងដែរ។ លោកក៏បានយកអក្សរដែលសរសេរដោយផ្ទាល់ដៃដែលមាននៅលើសំបុត្រកាលដែលផ្ញើអោយប៉ូលិសកាលពីមុន មកផ្ទៀងគ្នាជាមួយអក្សររបស់ឪពុកលោក លោកបានឃើញថាវាមើលទៅស្រដៀងគ្នា។

ម៉្យាងវិញទៀតលោកបានរកឃើញថា នៅថ្ងៃទី៩ មករា ឆ្នាំ១៩៤៧ ចំថ្ងៃដែល Elizabeth បាត់ខ្លួន Hodel បានទិញស៊ីម៉ង់ ៥០ប៉េមកចាក់បេតុង ដែលបាវនោះស្រដៀងនឹងបាវដែលច្រកសាកសពនាង។ មួយវិញទៀតលោក Hodel ក៏ជិះឡានព័ណ៌ខ្មៅកាលពីជំនាន់នោះដែរ ដែលឡាននោះមានព័ណ៌ដូចនឹងឡានសាក្សីរៀបរាប់ខាងលើ។

ទីបំផុត នៅឆ្នាំ២០១២ កុស្តតាងចុងក្រោយដែលឆ្កែហិតក្លិនរកបំណែកសាកសពរបស់ប៉ូលិស បានរកឃើញថា នៅបន្ទប់ក្រោមផ្ទះរបស់លោក Hodel មានក្លិនសាកសពកាលពីប្រហែល១០០ឆ្នាំមុន។

ទាំងអស់នេះសុទ្ធតែជាកុស្តតាងសំខាន់ដែល Steve មាន
តែក៏វាមិនទាន់គ្រប់គ្រាន់ដែរក្នុងការចោទប្រកាន់ថាឪពុករបស់គេជាឃាតករពិតប្រាកនោះទេ

**Ending:**

ជាចុងក្រោយ រឿងក្តីមួយនេះនៅតែរឿងក្តី ដែលដោះស្រាយមិនចេញរហូតមកដល់បច្ចុប្បន្ន។ សរុបមក
វាមានអាយុកាល៧០ឆ្នាំជាងហើយ។ រីឯឃាតកក៏ប្រហែលជាស្លាប់បាត់ហើយដែរ។
យ៉ាងណាក៏ដោយក៏រឿងក្តីនេះត្រូវបានអ្នកនិពន្ធជាច្រើនសិក្សា ហើយចងក្រងជាសៀវភៅ
និងបានផលិតជាខ្សែភាពយន្តដែរកាលពីឆ្នាំ២០០៦ ដោយមានចំណងជើងថា The Black Dahlia។

តាមរយះរឿងរ៉ាវខាងលើ យើងអាចស្វែងយល់បានថា ទោះបីជាយើងជួបបញ្ហាលំបាកយ៉ាងណាក៏ដោយ
មិនថាបញ្ហាស្នេហា ឬបញ្ហាគ្រួសារនោះទេ
ក៏យើងមិនត្រូវបណ្តោយអោយជីវិតយើងធ្លាក់ដល់ចំណុចសូន្យនោះដែរ។
យើងត្រូវចាំថាខ្សែជីវិតយើងមិនមែនមានតែមួយនោះទេ នៅមានមនុស្សល្អជាច្រើនចាំជួយយើងជានិច្ច
បើសិនជាចេះជួយខ្លួនឯង ក៏ប៉ុន្តែក៏មានមនុស្សមិនល្អចាំព្យាបាទយើងដែរ។ ដូច្នេះទៅណា
មកណាយើងត្រូវចេះការពារខ្លួននិងប្រយ័ត្នប្រយែងជានិច្ច។

**Link and resources**

https://www.biography.com/

https://crimereads.com/

https://www.history.com/

https://www.independent.com/

https://stmuhistorymedia.org/

https://www.123helpme.com/

https://www.theguardian.com/

https://vault.fbi.gov/

https://archives.fbi.gov/

https://www.novelsuspects.com/

https://stmuhistorymedia.org/